01157480

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 10 / 2015
ម៉ោង (Time/Heure): 11:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

002/19-09-2007-ECCC/TC
E1/343

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ អង្គារ ទី០៨ ខែ កញ្ញា ឆ្នាំ ២០១៥

## សវនាការលើអង្គសេចក្តី - ថ្ងៃ ៣២៤

រៀបចំដោយ៖ **ឯម ហ៊ាយ** និង **Roger PHILLIPS**

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ , ចៅក្រម Jean-Marc LAVERGNE , ចៅក្រម យូ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី , ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោក ឯម ហ៊ាយ, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Dale LYSAK, លោក Vincent DE WILDE D'ESTMAEL, លោក សេង លាង |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អារុណ, លោក លីវ សុវណ្ណ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| | |
|---|---|
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោកស្រី ទី ស្រ៊ីនណា, លោក វ៉ែន ពៅ, លោក ពេជ អង្គ, លោក ឡោ ជុនធី | |
| សាក្សី/ដើមបណ្តឹង៖ អ៊ុត សេន (2-TCW-813), ស៊ុះ ពន់យ៉ាមីន (2-TCCP-244) | |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ | |
| ផ្សេងៗ៖ លោក ម៉ៀច សុវណ្ណា, លោក ឡុង ង៉ែត, កញ្ញា ស្រី ណាក់, លោក លឿង សូភ័ក្រ, លោក កើយ វិញគឿម, កញ្ញា Joelle TRAMPERT | |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៩.០២ | បញ្ចប់ម៉ោង៖ ១៦.១៤ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១៣ | បញ្ចប់ម៉ោង៖១០.៣៤ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣៣ | បញ្ចប់ម៉ោង៖ ១៣.៣២ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៥០ | បញ្ចប់ម៉ោង៖ ១៥.០៣ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ៣៩ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ ក្រឡាបញ្ជី | ០៩.០៣ | ០៩.០៤ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០៤ | ០៩.០៦ |
| ការតាំងសំណួរទៅកាន់សាក្សី អ៊ុត សេន (2-TCW-813) | មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.០៦<br>១១.០២ | ១១.០៣<br>១៤.០៣ |
| សហព្រះរាជអាជ្ញាជំទាស់ទៅនឹងឯកសារយោងរបស់មេធាវីការពារក្តី នួន ជា ដែលមិនអនុញ្ញាតដាក់បញ្ចូលជាភស្តុតាង | អង្គជំនុំជម្រះ និងគ្រប់ភាគី | ០៩.៥៥ | ១០.០៥ |

| | | | |
|---|---|---|---|
| ការតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី សុះ ពន់យ៉ាមីន (2-TCCP-244) | អង្គជំនុំជម្រះ<br>សហមេធាវីនាំមុខ<br>សហព្រះរាជអាជ្ញា | ១៤.០៦<br>១៤.១០<br>១៥.៤១ | ១៤.១០<br>១៥.៤១<br>១៦.១២ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគី ទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការតាំងសំណួរទៅសាក្សី អ៊ិត សេន (2-TCW-813)</u>**

មេធាវីការពារក្ដី នួន ជា បានធ្វើការតាំងសំណួរទៅសាក្សី (2-TCW-813)។ បន្ទាប់មក មេធាវីការពារក្ដី ខៀវ សំផន បានធ្វើការតាំងសំណួរបន្ត។

**<u>ការជំទាស់របស់សហព្រះរាជអាជ្ញាទៅនឹងឯកសារយោងរបស់មេធាវីការពារក្ដី នួន ជា ថាមិនអាចទទួលយកជាភស្តុតាងបាន</u>**

មេធាវីការពារក្ដី នួន ជា បានសួរសំណួរទៅសាក្សី អ៊ិត សេន ពាក់ព័ន្ធនឹងការបះបោររបស់ជនជាតិចាម ។ នៅពេលដែលសហព្រះរាជអាជ្ញា ស្នើសុំឱ្យផ្ដល់នូវប្រភពឯកសារសម្រាប់សំណួរនេះ មេធាវីការពារក្ដី នួន ជា សំអាងទៅកាន់របាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស (E347.3)។ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា មេធាវីការពារក្ដី ខៀវ សំផន បានស្នើសុំឱ្យទទួលយកឯកសារនេះជាភស្តុតាងនៅក្នុងសំណុំរឿងបច្ចុប្បន្ន (E347) តែសំណើនេះត្រូវបានច្រានចោលដោយអង្គជំនុំជម្រះសាលាដំបូង (E347/1)។ សហព្រះរាជអាជ្ញា បានបញ្ចេញយោបល់ថា ការមិនផ្ដល់ប្រភពឯកសារបែបនេះ

មេធាវីការពារក្តី នួន ជា បានសួរសំណួរនាំមុខសាក្សីហើយ។ ក្រុមមេធាវីការពារក្តី ខៀវ សំផន បាន ស្នើសុំឱ្យមានការបំភ្លឺអំពីគោលជំហររបស់សហព្រះរាជអាជ្ញា ហាក់ដូចជាមិន ច្បាស់លាស់ពីយុត្តាធិការ របស់អង្គជំនុំជម្រះ ដែលថារាល់សំណួរដែលបានបានសួរសាក្សីម្នាក់ត្រូវតែផ្អែកលើឯកសារដែលបាន ទទួលយកជាភស្តុតាង។ អង្គជំនុំជម្រះសាលាដំបូង បានសន្និដ្ឋានថា ភាគីនានាគួរតែផ្តល់នូវប្រភពឯកសារ សម្រាប់ជាពត៌មាន ដែលពួកគេមានបំណងសួរតទល់គ្នាជាមួយសាក្សីនោះ។

**<u>ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី សុះ ពន់យ៉ាមីន (2-TCCP-244)</u>**

អង្គជំនុំជម្រះ បានតាំងសំណួរបឋមមួយចំនួនទាក់ទងនឹងអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋវេណី ព្រមទាំង ប្រាប់អំពីសិទ្ធិ និងករណីកិច្ចទៅដើមបណ្តឹងរដ្ឋប្បវេណី (2-TCCP-244)។ បន្ទាប់មក សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា បានធ្វើការតាំងសំណួរជាបន្តបន្ទាប់។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/5205 | D125/100 | 00221847-00221851; 00275161-00275164; 00293919-00293923 | Written Record of Interview of MAN Sen (Zain) | P | 00221850 | 00275163 - 00275164 | 00293922 |

Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/387 | D210/5 | 00379481-00379518; 00350200-00350231; 00441411-00441453 | Transcript of recorded interview with OUK Bunchhoeun on 04-08-1990 | P | 00379487 | 00350206 | 00441419 |
| E3/5195 | D125/78 | 00204428-00204433; 00242093-00242099; 00274716-00274722 | Written Record of Interview of IT Sen | P | 00204429 00204430 | 00242095 | 00274718 |
| E3/9334 | D125/78.1 | 00204434-00204439; 00204440-00204443; 00274723-00274726 | Annex 1: Interview of IT Sen in "The Cham Rebellion, Survivors' Stories from the Villages", Ysa Osman, Documentation series No. 9, DC-Cam, 2006 | P | 00204438 | 00204443 | 00274725 |

<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៦)
- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផនទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៥។ (១៦.១៤)

| <u>**កាលវេលាសវនាការបន្ត**</u> |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ឯម ហ៊ិយ** **Roger PHILLIPS**